YUNNAN DAILY PRESS GROUP
No.205

ប្រទេសចិន-ខេត្តយូនណាន

ទស្សនាម្ភៃប្រាំមួយ

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8101 ថ្ងៃសុក្រ ទី13 ខែធ្នូ ឆ្នាំ2019

បណ្ឌិតសភាចារ្យជួយយ៉ុង ចែករំលែកគ្នាអំពីលទ្ធផលសិក្សាស្រាវជ្រាវជាមួយប្រជាកសិករ

លោក ជួ យូវ យ៉ុង (រូបទី២ ខាងឆ្វេងដៃ) កំពុងពន្យល់ ពីការការពារសត្វល្អិតស៊ីដំណាំក្នុងស្រែចម្ការ

ប៉ុន្មានឆ្នាំមកនេះលោក ជួ-យូវយ៉ុងបណ្ឌិតសភាចារ្យនៃបណ្ឌិត្យសភាវិស្វកម្មចិននិងជាសាកលវិទ្យាធិការកិត្តិយសនៃសាកលវិទ្យាល័យកសិកម្ម ខេត្តយូនណាន បានដឹកនាំក្រុមការងារទៅធ្វើការក្នុងភូមិផ្សេងៗតាមតំបន់ព្រំដែននៅខេត្តយូនណានដើម្បីជួយកសិករក្នុងតំបន់អភិវឌ្ឍន៍មុខរបរផ្សេងៗតាមរយៈចំណេះដឹងវិទ្យាសាស្ត្រនិងកាត់បន្ថយភាពក្រីក្រ ។ នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៩លោកបានទទួលងារជា"គំរូក្នុងយុគសម័យថ្មី" ។ នេះជាកិត្តិយសដ៏ខ្ពង់ខ្ពស់សម្រាប់បុគ្គលគំរូដែលផ្តល់ដោយផ្នែកឃោសនាការមជ្ឈិមបក្សកុម្មុយនិស្តចិន ។

នៅឆ្នាំ២០១៥ បណ្ឌិត្យសភាវិស្វកម្មចិនបានកំណត់យកស្រុកស្វយ័តជនជាតិឡាគូឡានអាងខេត្តយូនណានជាកន្លែងគំរូសម្រាប់ឱ្យបណ្ឌិតសភាចារ្យចូលរួមការកាត់បន្ថយភាពក្រីក្រតាមរយៈបច្ចេកវិជ្ជា ។ កាលនោះ លោក ជួ យូវយ៉ុងដែលមានអាយុ ៦០ ឆ្នាំនោះបាននិយាយដោយមានភាពម្ចាស់ការថា "ខ្ញុំនៅក្មេង ឱ្យខ្ញុំទៅធ្វើ!"

ប្រជាជនក្នុងស្រុកឡានអាងនេះភាគច្រើនជាជនជាតិឡាគូដែលបានរស់នៅក្នុងតំបន់ភ្នំជាច្រើនជំនាន់ហើយ។ ពួកគេមិនចេះនិយាយភាសាចិនកុកងឺ ហើយមានការរស់នៅក្រីក្របំផុត។ លោក ជួ យូវយ៉ុងមានការយល់ដឹងយ៉ាងច្បាស់លាស់ថា បើចង់ជួយប្រជាកសិករកាត់បន្ថយនូវភាពក្របីបញ្ហាប្រឈមដែលត្រូវដោះស្រាយជាបន្ទាន់នោះគឺ"តើកសិករត្រូវដាំអ្វីខ្លះ?" ស្រុកឡានអាងកម្រធ្លាក់ភ្លៀងនៅរដូវរងា ហើយមិនធ្លាក់ទឹកកកដែលសក្តិសមនឹងការដាំដុះដំឡូងបារាំងនិងមានប្រៀបលើគេក្នុងការដាំដំឡូងបារាំងបើប្រៀបធៀបនឹងតំបន់ផ្សេងៗទៀត ។

ជាដំបូងអ្នកស្រុកក្នុងតំបន់មិនព្រមដាំដំឡូងបារាំងទេ ។ លោកជួ យូវ-យ៉ុងមានតែទៅសាកល្បងដាំដំឡូងបារាំងក្នុងដីស្រែជាសមូហភាពដែលមានទំហំមិនដល់ ៧ ហិកតា ។ នៅរដូវផ្តាំរីកនៃឆ្នាំ២០១៧ដីស្រែគំរូរបស់លោកបានទទួលផលដ៏ច្រើនដោយប្រមូលបានផលដំឡូងបារាំង៥០ តោនក្នុងមួយហិកតា ។ បើគិតតាមតម្លៃទីផ្សារនៃដំឡូងបារាំងគឺ ៣ យាន់មួយគីឡូក្រាម គេអាចទទួលបានចំណូលជិត ១៥ម៉ឺនយាន់ក្នុងមួយហិកតា ។ នេះបានធ្វើឱ្យប្រជាកសិករក្នុងតំបន់ចាប់ផ្តើមដាំដំឡូងបារាំងតាមសំណើរបស់លោក ។

ការដាំដំឡូងបារាំងគ្រាន់តែជាការសាកល្បងទី១ របស់លោក ជួ-យូវយ៉ុង ។ ក្រៅពីដំឡូងបារាំងលោកបានទទួលការជោគជ័យក្នុងការសិក្សាស្រាវជ្រាវពីបច្ចេកទេសដាំថ្នាំចិនសែក្នុងព្រៃឈើ ។

លោកបានផ្ទេរបច្ចេកទេសរបស់លោកទៅឱ្យប្រជាកសិករក្នុងតំបន់ដោយឥតយក ថ្លៃតែលោកមានលក្ខខ័ណ្ឌតែមួយគឺមិនអាចដាក់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតទេហើយត្រូវយកប្រាក់ចំណូល១៥ភាគរយសម្រាប់ជំរុញការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ ។ ចំណូល១៥ភាគរយ នេះគឺជាចំណូលរបស់លោកតាមរយៈការចូលភាគហ៊ុនតាមបច្ចេកទេស ។

មិនតែប៉ុណ្ណោះលោកបានរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសដើម្បីជួយប្រជាកសិករកាត់បន្ថយភាពក្រីក្រ ។ លោកបានបង្កើតវគ្គបណ្តុះ-បណ្តាលបច្ចេកទេសសម្រាប់កាត់បន្ថយភាពក្រីក្ររបស់បណ្ឌិត្យសភាវិស្វកម្មចិនជាលើកទី១ ក្នុងប្រទេសចិនហើយបានអញ្ជើញឱ្យបណ្ឌិតសភាចារ្យ និងអ្នកជំនាញការល្បីឈ្មោះទៅបង្រៀនកសិករដោយផ្ទាល់ដើម្បីណែនាំឱ្យពួកគេចេះដាំដំណាំ ។ ក្រៅពីថ្នាំចិនសែ និងដំឡូងបារាំងលោកបានរៀបចំវគ្គបណ្តុះ-បណ្តាលអំពីបច្ចេកទេស២៤ទៀត រួមមានបច្ចេកទេសដាំបន្លែស្លឹកតែ ព្រៃឈើ និងចិញ្ចឹមសត្វជ្រូកជាដើមហើយបានបណ្តុះបណ្តាលកសិករជាង១.៥០០ នាក់ ។ ក្នុងចំណោមនោះមានសិក្ខាកាម ៩០ភាគរយ បានជ្បៀសផុតពីភាពក្រីក្រ និងមានសិក្ខាកាម៥០ភាគរយបានជួយញាតិមិត្តកាត់បន្ថយភាពក្រីក្រ ។ ជាពិសេសមានសិក្ខាកាមមួយចំនួនបានជួយកាត់បន្ថយភាពក្រីក្រនៃភូមិទាំងមូល។

នៅខែវិច្ឆិកាឆ្នាំនេះ លោក ជួ-យូវយ៉ុងបានបង្កើតកិច្ចសហប្រតិបត្តិការជាមួយវេបសាយ"Buy Together"នៃប្រទេសចិនក្នុងការរៀបចំវគ្គបណ្តុះ-បណ្តាលពាណិជ្ជកម្មអេឡិចត្រូនិកតាមទីជនបទ ដើម្បីផ្សព្វផ្សាយពីកសិផលរបស់កសិករក្រីក្រជួយពួកគេលក់កសិផលរបស់ខ្លួននិងទទួលបានចំណូលកាន់តែច្រើន ៕

ការកាត់បន្ថយភាពក្រីក្របានឈានចូលដំណាក់កាលគន្លឹះដែលខាំឆ្អឹងរឹង និងពុះពារខុបសគ្គពិបាកជាងគេ ។ យើងត្រូវរួមសាមគ្គីគ្នាជាផ្លូងមួយដើម្បីសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្រអាស្រ័យលើឆន្ទៈកាន់តែមោះមុត ទស្សនៈកាន់តែជាក់ច្បាស់ វិធានការកាន់តែត្រឹមត្រូវនិងកម្លាំងកាន់តែខ្លាំងក្លាហើយមិនអាចធ្វើឱ្យតំបន់ក្រីក្រណាមួយ ឬជនក្រីក្រណាមួយដើរនៅក្រោយគេ ៕

(ដកស្រង់ចេញពីសុន្ទរកថារបស់ឯកឧត្តមស៊ី ជីនភីងដែលថ្លែងក្នុងកិច្ចប្រជុំអំពីការងារកាត់បន្ថយភាពក្រីក្រនៃមជ្ឈិមបក្សកុម្មុយនិស្តចិននៅ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៥)

ប៉ាន់ច្រាក់ស្រុកហ៊ឺឈីងយកកូនញញួរវាយដំរាប់ពាន់ឆ្នាំ

ប៉ាន់ច្រាក់ស្រុកហ៊ឺឈីង

"កវែងមាត់តូចពោះធំពាក់មួកមូលមានផ្តាលើគួខ្លួន"។ ពាក្យនេះបានបង្ហាញពីចំណុចពិសេសនៃប៉ាន់ច្រាក់ស្រុកហ៊ឺឈីង ។ បើនិយាយអំពីសិប្បកម្មធ្វើគ្រឿងច្រាក់ផ្សេងៗនៅខេត្តយូណានស្រុកហ៊ឺឈីងនៃមណ្ឌលស្វយ័តជនជាតិប៉ៃតាលីមានឈ្មោះល្បីល្បាញ ជាងគេ ។

តាមពិតការធ្វើប៉ាន់ច្រាក់មិនមែនជារឿងងាយមួយទេ។ អ្នកបច្ចេកទេសត្រូវធ្វើតាមលំដាប់ចំនួន២២ និងវាយដំជាង ២ សែនដង ទើបអាចធ្វើបាន ប៉ាន់ច្រាក់មួយ។ លោកលីហ្គូម៉ែង អ្នកបន្តវេននៃសិប្បកម្មធ្វើគ្រឿងច្រាក់នៅស្រុកហ៊ឺឈីងដែលជាបេតិកភណ្ឌវប្បធម៌អរូបីនៃប្រទេសចិនបានបញ្ជាក់ថា តាំងពីសម័យណាចារ្យវែងមកអ្នកស្រុកតាលីក៏ចាប់ផ្តើមយកវត្ថុធាតុដើមក្នុងតំបន់ដើម្បីធ្វើគ្រឿងច្រាក់។ ក្នុងចំណោមនោះសិប្បកម្មរបស់អ្នកស្រុកហ៊ឺឈីងមានប្រវត្តិសាស្ត្រយូរលង់ជាងគេ ពោលគឺបានមានប្រវត្តិជាង ១.០០០ឆ្នាំទៅហើយ ។ លោកបន្តទៀតថា ក្នុងមួយជីវិតរបស់អ្នកស្រុកនៅតាលីមិនអាចខ្វះគ្រឿងច្រាក់បានទេ។ ពាក្យថា "យកកូនញញួរវាយដំរាប់ពាន់ឆ្នាំ "គឺចង្អុលសំដៅលើគ្រឿងច្រាក់។

លោកលី ហ្គូម៉ែង កើតនៅស្រុកហ៊ឺឈីង ហើយមានចំណង់ចំណូលចិត្តចំពោះសិប្បកម្មធ្វើគ្រឿងច្រាក់តាំងពីតូចមក។ នៅឆ្នាំ១៩៩៨ លោកបានបញ្ចប់ការសិក្សាពីសាលារៀនហើយចាប់ផ្តើមរៀនធ្វើប៉ាន់ច្រាក់។ ក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅនោះ លោកមិនដែលបញ្ឈប់ការវាយដំដោយប្រើកូនញញួរទេ។ ប៉ាន់ច្រាក់មួយអាចបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់លោក។ នៅឆ្នាំ ២០១០ លោកបានធ្វើប៉ាន់ច្រាក់ "ខូវតា" ទី១ តាមវិធីបុរាណ។ នៅឆ្នាំ២០១១ លោកបានធ្វើប៉ាន់ច្រាក់ "ឃូសាន" ដោយផ្ទាល់ដៃ។ សព្វថ្ងៃរោងសិប្បកម្មរបស់លោកមានជាងសិប្បកម្ម ១៨០ នាក់ និងបុគ្គលិកការងារ២២នាក់៕ **ដោយលីឈីនយីង**

ការប្រកួតរត់ម៉ារ៉ាតុងក្រុងគុនមីងឆ្នាំ២០១៩ នៃអង្គការសហប្រតិបត្តិការក្រុងស្បៀងហៃបើកការប្រកួតជាផ្លូវការ

ព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩ ការប្រកួតរត់ម៉ារ៉ាតុងក្រុងគុនមីងឆ្នាំ២០១៩ នៃអង្គការសហប្រតិបត្តិការក្រុងស្បៀងហៃ បានបើកការប្រកួតជាផ្លូវការនៅក្រុងគុនមីងនៃខេត្តយូនណាន។ការប្រកួតនេះត្រូវបែងចែកជាការ ប្រកួតសំខាន់ចំនួន ៤ គឺការរត់ ម៉ារ៉ាតុងពេញម៉ារ៉ាតុងពាក់កណ្តាលការរត់ចម្ងាយដើម្បីសុខភាពសាធារណជន និងការរត់ចម្ងាយដោយកូន និងឪពុក-ម្តាយ ដែលបានទាក់ទាញបេក្ខជន បេក្ខនារី២ម៉ឺននាក់នៃប្រទេសនិងតំបន់ ចំនួន៣៥លើ ពិភពលោក ។

តាំងពីឆ្នាំ២០១៦ស្បៀងមកការប្រកួតរត់ម៉ារ៉ាតុងក្រុងគុនមីងនៃអង្គការ សហប្រតិបត្តិការក្រុងស្បៀងហៃបានរៀបចំនៅក្រុងគុនមីង៤លើកហើយ។ការប្រកួតនេះបានប្រែក្លាយពីការប្រកួត មេដាយសំរិទ្ធិទៅជាការប្រកួតមេដាយមាសនៃសមាគមអត្តពលកម្មចិនហើយបានត្រូវសមាគមអត្តពលកម្មអន្តរជាតិប្រសិទ្ធនាមថាជា "ការប្រកួតពានរង្វាន់សំរិទ្ធិ" និងបានត្រូវជ្រើសរើសជាការប្រកួតកីឡាទេសចរណ៍ល្បីឈ្មោះប្រចាំឆ្នាំ២០១៩ ៕

(កាសែតយូនណានដេលី)

ការបំបែកអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រ-អាជីវកម្មកែលម្អបរិយាកាសពាណិជ្ជកម្ម

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ សាលារដ្ឋបាលខេត្តយូនណាន បានប្រកាសជាផ្លូវការនូវ "គម្រោងសាកល្បងអនុវត្តប្រព័ន្ធបំបែកអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រអាជីវកម្មក្នុងតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន (ខេត្តយូនណាន)" ។ ចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩តទៅ ផ្នែកគុនមីងហុងហ៊ី និងតឺហុងនៃតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន (ខេត្តយូនណាន) ចាប់ផ្តើមអនុវត្តគម្រោង "បំបែកអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រអាជីវកម្ម"។

វិញ្ញាបនបត្រអាជីវកម្មគឺចង្អុលសំដៅលើវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មដែលផ្តល់ដោយស្ថាប័នគ្រប់គ្រងឧស្សាហកម្ម និងពាណិជ្ជកម្ម ចំណែកអាជ្ញាប័ណ្ណ គឺអាជ្ញាប័ណ្ណអាជីវកម្មដែលផ្តល់ដោយស្ថាប័នគ្រប់គ្រងវិស័យផ្សេងៗ។ ការជំរុញកំណែទម្រង់ "បំបែកអាជ្ញាប័ណ្ណនិងវិញ្ញាបនបត្រអាជីវកម្ម" អាចផ្តល់ការងាយស្រួលដល់សហគ្រាសក្នុងការបំពេញបែបបទនៃការធ្វើអាជីវកម្ម ព្រមទាំងអាចកែលម្អបរិយាកាសពាណិជ្ជកម្ម។ តាមគម្រោងនេះខេត្តយូនណាននឹងកែសម្រួលនីតិវិធីនៃការបំពេញបែបបទអាជីវកម្មក្នុងផ្នែកគុនមីងហុងហ៊ី និងតឺហុងនៃតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន (ខេត្តយូនណាន) ដើម្បីបង្កើតបរិយាកាសពាណិជ្ជកម្មដែលដំណើរការតាមក្បួនទីផ្សារ និងច្បាប់ ហើយមានលក្ខណៈអន្តរជាតូបនីយកម្ម៕

ដោយជួ ង៉ាន និង លី ហ៊ុងឈាង